00634782

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

-2-

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

*តាងនាមប្រជាពលរដ្ឋកម្ពុជា និងអង្គការសហប្រជាជាតិ ដោយអនុវត្តច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីចោទប្រកាន់ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/២១-១០-២០១០/អ.វ.ត.ក.-អ.ប.ជ.(១៥)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 01 / 2011
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សមាសភាពចៅក្រម: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នុំយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុធី

កាលបរិច្ឆេទ: ថ្ងៃទី១២ ខែមករា ឆ្នាំ ២០១១

---

**សាធារណៈ:**

**សាលដីកាលើបណ្ដឹងឧប្បត្តិហេតុរបស់ ខៀវ សំផន ដែលមានគោលដៅផ្អាកភ្លាមៗ និងជាស្ថាពរនូវនីតិវិធី ដោយមូលហេតុមានការរំលោភលើនីតិវិធី**

---

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew T. CAYLEY

**ជនជាប់ចោទ**
ខៀវ សំផន

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Siegfried BLUNK

**សហមេធាវីការពារក្តី**
ស សុវាន
Jacques VERGÈS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អង្គបុរេជំនុំជម្រះ" និង "អ.វ.ត.ក.") បានទទួលនូវ "បណ្តឹងឧបាស្តិហេតុដើម្បីផ្អាកភ្លាមៗ និងជាស្ថាពរនូវនីតិវិធីដែលធ្វើឡើងប្រឆាំងនឹង លោក ខៀវ សំផន ដោយមូលហេតុមានការរំលោភលើនីតិវិធី" ("សំណើសុំ") ដែលបានដាក់ដោយ ខៀវ សំផន កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០[១]។

## I. បទបង្ហាញសង្ខេបអំពីសំណើសុំ

១. សំណើសុំត្រូវបានដាក់ស្របទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ដែលបានដាក់កាលពី ថ្ងៃ ទី១៨ ខែតុលា ឆ្នាំ២០១០ ប្រឆាំងទៅនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ចេញថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១០ ("បណ្តឹងឧទ្ធរណ៍")[២]។ ផ្អែកលើទ្រឹស្តីនៃការរំលោភលើនីតិវិធី ខៀវ សំផន សូមស្នើដល់ អង្គបុរេជំនុំជម្រះឱ្យធ្វើការពិនិត្យមើលលើករណីនៃការរំលោភនីតិវិធី ដូចដែលបានចោទប្រកាន់ ឱ្យធ្វើ ការបដិសេធក្នុងការបញ្ជូនសំណុំរឿងគាត់ទាំងមូលទៅកាន់អង្គជំនុំជម្រះសាលាដំបូង ឱ្យធ្វើការសម្រេច បញ្ឈប់នីតិវិធី និងបង្គាប់ឱ្យមានការដោះលែងរូបលោក[៣]។ ភាគីដទៃទៀតពុំបានដាក់ចម្លើយតបទៅនឹង សំណើសុំនេះទេ។

២.សំណើសុំបានផ្អែកលើទឡ្ហីករណ៍សំខាន់ៗចំនួន៣។ ជាបឋម ខៀវ សំផន បានអះអាងថា រូបគាត់គឺ ជាជនរងគ្រោះនៃយុត្តិនិសេធ ដែលអូសបន្លាយពាក់ព័ន្ធនឹងការបកប្រែឯកសារ ដោយមូលហេតុថា (១) ឯកសារមួយចំនួនមិនត្រូវបានបកប្រែ ហើយ (២) ការបកប្រែឯកសារធ្វើឡើងដោយគ្មានគុណភាព ព្រម ទាំងគ្មានការត្រួតពិនិត្យទៅលើគុណភាព។ គាត់បានបន្ថែមទៀតថា រូបគាត់គឺជាជនរងគ្រោះនៃការរំលោភ

---

[១] បណ្តឹងឧបាស្តិហេតុដើម្បីផ្អាកភ្លាមៗ និងជាស្ថាពរ នូវនីតិវិធីដែលធ្វើឡើងប្រឆាំងនឹងលោក ខៀវ សំផន ដោយមូលហេតុមាន ការរំលោភលើនីតិវិធី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារលេខ ១ ("សំណើសុំ")។

[២] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/4/3(បណ្តឹងឧទ្ធរណ៍), ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

[៣] សំណើសុំ កថាខណ្ឌ៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00634784



ជាប្រព័ន្ធ និងទាំងស្រុងទៅលើសិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ ដែលការរំលោភនោះកើតចេញមកអំពី (១) អវត្តមាននៃការពិនិត្យសំណុំរឿង និង (២) ការមិនគោរពគោលការណ៍នីត្យានុកូលភាព។ ជាចុងក្រោយ សំណើសុំបានលើកឡើងអំពីចរិតលក្ខណៈ*អសព្វភាព*របស់ស្ថាប័នជម្រះក្តី ដែលបណ្តាលមកពី (១) រយៈពេលពុំសមស្រប និងគ្មានមូលដ្ឋានត្រឹមត្រូវ ព្រមទាំង (២) សច្ចាធារណ៍ជាសាធារណៈនៃពិរុទ្ធភាព។ ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានថា រូបគាត់បានទទួលរងនូវព្យសនកម្មមួយពិតប្រាកដ និងមិនអាចជួសជុលបាន។

៣. ដោយបានស្នើសុំឱ្យមានបើកសវនាការជាសាធារណៈមួយ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ខៀវ សំផនបានស្នើសុំថា ទឡ្ហីករណ៍ទាំងឡាយដែលបានលើកឡើងនៅក្នុងសំណើសុំ ត្រូវតែបានទទួលយកក្នុងកិច្ចពិភាក្សាលើបណ្តឹងឧទ្ធរណ៍នេះ។

## II. យុត្តាធិការរបស់អង្គជំនុំជម្រះ និងភាពដែលអាចទទួលយកបាននៃសំណើសុំ

៤. ខៀវ សំផន បានផ្អែកលើមាត្រា៣៣នៃច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់ស្តីពី អ.វ.ត.ក.) និងវិធាន២១(១)(ក)នៃវិធានផ្ទៃក្នុង ដើម្បីលើកឡើងអំពីយុត្តាធិការជាន់ដំបូងនៃអង្គបុរេជំនុំជម្រះ។ ក្នុងការផ្តល់សំអាងដល់សំណើសុំរបស់គាត់ ខៀវ សំផន បានលើកឡើងថា អង្គបុរេជំនុំជម្រះដែលជាអ្នកទទួលសំណុំរឿង គឺជាស្ថាប័នតែមួយគត់ ដែលមានយុត្តាធិការក្នុងការទទួលយកសេចក្តីសន្និដ្ឋាននានារបស់មេធាវីការពារក្តី ក្នុងដំណាក់កាលជាន់ដំបូងនិងឧទ្ធរណ៍។ គាត់បានបន្ថែមទៀតថា ក្នុងការអនុវត្តវិធាន៧៦(១)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ គឺជាស្ថាប័នតែមួយគត់ ដែលមានសិទ្ធិសម្រេចបន្ត ឬបញ្ឈប់នីតិវិធី។ ហើយជាចុងក្រោយ ខៀវ សំផន បានចាត់ទុកអង្គបុរេជំនុំជម្រះជាស្ថាប័ន ដែលមានអំណាចមិនអាចកាត់ផ្តាច់បាន និងមានកាតព្វកិច្ចជំនុំជម្រះលើសំណើសុំ[៤]។

---

[៤] សំណើសុំ កថាខណ្ឌ១៨ ដល់ ២០។

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណើសុំពុំមានលក្ខណៈជាបណ្តឹងឧទ្ធរណ៍ ហើយក៏ពុំមានលក្ខណៈជាបណ្តឹងសុំមោឃៈភាព ដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន ស្របតាមវិធាន៧៣ នៃវិធានផ្ទៃក្នុងដែរ។ ដោយឡែក វិធាន២១(១)(ក)នៃវិធានផ្ទៃក្នុង បានចែងថា "ដំណើរការនីតិវិធីនៅក្នុង អ.វ.ត.ក. ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាឲ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។ ម្យ៉ាងទៀត អង្គបុរេជំនុំជម្រះបានរំលឹកអំពីសេចក្តីសម្រេចពីមុនរបស់ខ្លួន ដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធចោលសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុមានការរំលោភលើនីតិវិធី ("សេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ")[៥]។ នៅក្នុងសេចក្តីសម្រេចនេះ "យល់ឃើញថា ច្បាប់ជាតិពុំបានកំណត់អំពីយន្តការក្នុងការដោះស្រាយករណីដែលមានការរំលោភលើនីតិវិធី" និងដោយផ្អែកលើការអនុវត្តជាអន្តរជាតិ អង្គបុរេជំនុំជម្រះចាត់ទុកថា "យុត្តិធម៌ គឺជាធាតុផ្សំដ៏សំខាន់ ដែលត្រូវប្រកាន់យកនៅគ្រប់ដំណាក់កាលនៃនីតិវិធីក្នុង អ.វ.ត.ក."។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ខ្លួនមានយុត្តាធិការលើករណីបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីបញ្ហាចម្បងពាក់ព័ន្ធនឹងយុត្តិធម៌ ហើយធ្វើការពិនិត្យលើបណ្តឹងឧទ្ធរណ៍នេះ ដូចជាអង្គបុរេជំនុំជម្រះបានទទួលពាក្យបណ្តឹងដោយផ្ទាល់នាដំណាក់កាលដំបូងអញ្ចឹងដែរ[៦]។

៦.ជាក់ស្តែង អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតដែលបានចេញដីកាដំណោះស្រាយ ពុំបានទទួលសំណុំរឿងទៀតទេ ហើយដោយបានទទួលបណ្តឹងឧទ្ធរណ៍ដែលប្រឆាំងទៅនឹងដីកានេះ អង្គបុរេជំនុំជម្រះ គឺជាស្ថាប័នតែមួយគត់ដែលដឹងអំពីសំណុំរឿងនៅក្នុងដំណាក់កាលនៃនីតិវិធី ហើយអាចពិនិត្យបណ្តឹងដែលមានលក្ខណៈជាសំណើសុំ។ បញ្ហាដែលពាក់ព័ន្ធថា តើអង្គបុរេជំនុំជម្រះមានយុត្តាធិការក្នុងការដោះស្រាយលើសំណើសុំដែរឬទេ សម្តៅទៅលើការកំណត់ថា តើសំណើសុំនេះបានលើកឡើងអំពីបញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងយុត្តិធម៌ ដែលអង្គបុរេជំនុំជម្រះត្រូវធ្វើការពិនិត្យ ដើម្បីធានាបាននូវសិទ្ធិ

---

[៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ")។

[៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ១៤, ១៧ និង ១៨។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ស្របតាមវិធាន២១(១)(ក)នៃវិធានផ្ទៃក្នុង ហើយដែលបញ្ហាទាំងនោះ មិនអាចត្រូវបានដោះស្រាយផ្សេងពីនេះបានទេ។ អង្គបុរេជំនុំជម្រះចាត់ទុកថា បញ្ហានេះមានជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងភាព ដែលអាចទទួលយកបាននៃសំណើសុំ ហើយអង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យលើសំណើសុំ ដោយផ្អែកលើបរិបទនេះ។

៧. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះបានធ្វើការសិក្សាលើបទដ្ឋានអន្តរជាតិ ដើម្បីធ្វើការកំណត់លក្ខណវិនិច្ឆ័យសម្រាប់ពិនិត្យលើសំណើសុំព្យួរដោយមូលហេតុមានការរំលោភលើនីតិវិធី[៧]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "ទ្រឹស្តីនៃការរំលោភលើនីតិវិធី អាចត្រូវបានលើកឡើងតែក្នុងករណី ដែលគេសង្កេតឃើញថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភយ៉ាងជាក់ស្តែង" ហើយថា "អំណាចក្នុងការព្យួរការអនុវត្តនីតិវិធី ដោយផ្អែកលើមូលដ្ឋាននេះ គឺជាអំណាចឆន្ទានុសិទ្ធិ ពោលគឺជាការសម្រេចរបស់តុលាការ ក្នុងការរកឲ្យឃើញថា ការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ឬជនត្រូវចោទមានលក្ខណៈជាក់ស្តែង រហូតរាំងចៅក្រមក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន"[៨]។ម្យ៉ាងទៀត អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា "ការព្យួរនីតិវិធី គឺជាវិធានការក្តៅ

---

[៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ១៩ ដល់ ២៨។

[៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ២៦។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង* Thomas Lubanga *Dyilo*, ICC-01/04-01/06 (OA4), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ លើអញ្ញត្រកម្មអសមត្ថកិច្ចរបស់តុលាការ លើកឡើងដោយក្រុមមេធាវីការពារក្តី អនុលោមតាមមាត្រា ១៩-២-ក នៃលក្ខន្តិកៈ, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ២៨, នៅក្នុងនីតិវិធីប្រឆាំងនឹង *Florence Hartman*, សំណុំរឿង IT-02-54-R77.5, *Reasons for Decsion on the Defence Mortion for Stay of Proceeding for Abuse of Process,* អង្គជំនុំជម្រះសាលាដំបូង ចាត់តាំងជាពិសេសដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ៤; *រដ្ឋអាជ្ញា តទល់នឹង* *Dragan Nikolić*, សំណុំរឿង IT-94-5-PT, សាលដីកាលើអញ្ញត្រកម្មអសមត្ថកិច្ចរបស់តុលាការលើកឡើងដោយក្រុមការពារក្តី អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៩ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ១១ ដោយលើកពីសំណុំរឿង *Jean-Bosco Barayagwiza* *តទល់នឹង រដ្ឋអាជ្ញា* សំណុំរឿង ICTR-97-19-AR72, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការឧក្រិដ្ឋកម្មជាតិសម្រាប់ប្រទេសរវ៉ាន់ដា ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ៧៣ និង ៧៧ និងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Radovan Karadžić* សំណុំរឿង IT-95-5/18-PT,

បំផុតដែលត្រូវអនុវត្តតែក្នុងករណីពិសេស និងធ្ងន់ធ្ងរនៃការរំលោភលើសិទ្ធិរបស់ជនត្រូវចោទដែលមិនអាចរារាំងបាន ឬប្រឆាំងទៅនឹងគំនិតដែលថា តុលាការជាអ្នកកាត់សេចក្ដីតាមតែឆន្ទៈរបស់ខ្លួននោះ។ មានតែក្នុងករណីពិសេសនៃ*ការរំលោភបំពានជាក់ស្ដែង*ប៉ុណ្ណោះទេ ដែលការចាត់វិធានការណាមួយត្រូវបានចាត់ទុកថា មានលក្ខណៈសមាមាត្រនោះ”[៩]។ ដូច្នេះ អង្គបុរេជំនុំជម្រះបានអនុវត្តលក្ខណៈវិនិច្ឆ័យតឹងរ៉ឹងក្នុងការសន្និដ្ឋានថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ពិតជាបានទទួលរងនូវអនិយ័តភាពធ្ងន់ធ្ងរ ឬមានការរំលោភជាក់ស្ដែងទៅលើសិទ្ធិរបស់ពួកគេនោះ[១០]។

៨. មុននឹងអាចធ្វើការពិនិត្យលើខ្លឹមសារនៃការចោទប្រកាន់ដូចបញ្ជាក់នៅក្នុងសំណើសុំ នៅក្នុងករណីដែលការចោទប្រកាន់នោះមានមូលដ្ឋានសមស្រប អង្គបុរេជំនុំជម្រះត្រូវតែធ្វើការសន្និដ្ឋានថា ការរំលោភបំពានដូចបានចោទប្រកាន់លើកឡើងពីបញ្ហាយុត្តិធម៌ ដែលមានលក្ខណៈធ្ងន់ធ្ងរ និងជាក់ស្ដែង ដើម្បីឱ្យមានការបញ្ឈប់នូវដំណើរការនីតិវិធី ដោយមូលហេតុមានការរំលោភលើនីតិវិធី។ ប្រសិនណាជាពុំមែនករណីដូច្នោះទេ គេមិនត្រូវធ្វើការពិនិត្យលើខ្លឹមសារនៃការចោទប្រកាន់ទាំងនោះទេ។

៩. អង្គបុរេជំនុំជម្រះសម្គាល់ឃើញថា ទឡ្ហីករណ៍មួយចំនួនរបស់មេធាវីការពារក្ដីមានលក្ខណៈទូលំទូលាយ ឬមានមូលដ្ឋានពុំគ្រប់គ្រាន់។ អង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍បែបនេះឡើយ ដោយហេតុថា វាជាភារៈរបស់ ខៀវ សំផន ក្នុងការផ្ដល់អំណះអំណាងដល់សំណើសុំរបស់ខ្លួន។

១០. ខៀវ សំផន បានលើកឡើងថា គាត់គឺជាជនរងគ្រោះនៃយុត្តិនិសេធ ដែលមានលក្ខណៈអូសបន្លាយពាក់ព័ន្ធនឹងការបកប្រែឯកសារ។ គាត់បានបញ្ជាក់ថា គាត់ពុំបានទទួលនូវការបកប្រែជាភាសាបារាំង នូវជើងទំព័រនៃដីកាដំណោះស្រាយ (៣៣៥ទំព័រ) នូវឯកសារភស្ដុតាងមួយចំនួន នូវដីកាសន្និដ្ឋានស្ថាពរ សេចក្ដី

---

សេចក្ដីសម្រេចលើសំណើសុំបដិសេធបទចោទប្រកាន់ ដោយមូលហេតុរំលោភនីតិវិធី អង្គជំនុំជម្រះសាលាដំបូង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៩។

[៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ២៨។

[១០] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ២៧ និង ២៨។

00634788



សម្រេចចំនួន២៣២ និងឯកសារដែលដាក់ដោយភាគី ចំនួន៣៨៥០ ហើយគាត់ទើបតែបានទទួលដោយយឺតយ៉ាវនូវការបកប្រែភាសាលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលគាត់អះអាងថា ឯកសារអស់ទាំងនេះត្រូវតែបានបកប្រែជាភាសាបារាំង[១១]។ គាត់បានអះអាងទៀតថា ដោយសារតែការបកប្រែនេះ គាត់ "ត្រូវបានដកហូតសិទ្ធិក្នុងការចូលរួមក្នុងដំណើរការនីតិវិធី និងលទ្ធភាពក្នុងការអនុវត្តសិទ្ធិក្នុងការឆ្លើយតបឱ្យបានពេញលេញ និងទាំងស្រុង"[១២]។

១១. អង្គបុរេជំនុំជម្រះបានរំលឹកពីសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងទៅនឹងដីកាដែលកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងការបកប្រែឯកសារ ("សេចក្តីសម្រេចពាក់ព័ន្ធនឹងការបកប្រែឯកសារ") ដែលនៅក្នុងសេចក្តីសម្រេចនោះ អង្គបុរេជំនុំជម្រះបានសម្រេចថា ពុំមានបញ្ញត្តិដាច់ខាតណាមួយ ដែលតម្រូវឱ្យទទួលបាននូវការបកប្រែឯកសារទាំងអស់ ទៅជាភាសាបារាំងឡើយ[១៣]។ ម្យ៉ាងទៀត អង្គបុរេជំនុំជម្រះបានរំលឹកពីដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងការបកប្រែឯកសារ ("ដីកាសម្រេចលើការបកប្រែឯកសារ") ដែលតាមរយៈដីកានោះ ការបកប្រែឯកសារទៅជាភាសាបារាំងត្រូវតែបានផ្តល់សម្រាប់ដីកាដំណោះស្រាយ សម្រាប់ធាតុផ្សំភស្តុតាងនានា ដែលឯកសារនេះបានផ្អែកលើ សម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាស្ពាពរ ក៏ដូចជាសម្រាប់រាល់សេចក្តីសម្រេច និងដីកាទាំងឡាយដែលចេញដោយចៅក្រមនានា[១៤]។ ពាក់ព័ន្ធនឹងការបកប្រែឯកសារភស្តុតាង អង្គបុរេជំនុំជម្រះបានផ្អែកទៅលើសេចក្តីសម្រេចរបស់ខ្លួន ពាក់ព័ន្ធនឹង

---

[១១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ កថាខណ្ឌ២៥ និង ២៧; *ស្ថិតិសំណុំរឿង 00២ គិតមកត្រឹមថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០* ដាក់ដោយផ្នែកតម្កល់ឯកសារឯកសារ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ៖ 00៦១៧៣៤៨។

[១២] សំណើសុំ កថាខណ្ឌ២៩។

[១៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ D190/I/20 ("សាលដីកាទាក់ទងនឹងការបកប្រែ") កថាខណ្ឌ៤០ ដល់ ៤២។

[១៤] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ A109 ("ដីកាសម្រេចទាក់ទងនឹងការបកប្រែ") កថាខណ្ឌ ខ៤ និង គ១ ដល់ គ៣; *សូមមើលផងដែរ* សាលដីកាទាក់ទងនឹងការបកប្រែ កថាខណ្ឌ៣៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

បណ្តឹងស្នើសុំឱ្យមានការបកប្រែឯកសារទាំងអស់ ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការចេញដីកាដំណោះស្រាយ ដែលដីកានោះបញ្ជាក់អំពីបទបញ្ញត្តិ ដែលត្រូវអនុវត្តចំពោះការបកប្រែឯកសារទាំងនោះ[១៥]។ ជាទីបញ្ចប់ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាសម្រេចអំពីការបកប្រែឯកសារពុំបានកំណត់អំពីរយៈពេលសម្រាប់ការបកប្រែឯកសារឡើយ។

១២. អង្គបុរេជំនុំជម្រះបានពិនិត្យមើលបញ្ជីឯកសារ ដែលមិនទាន់បានបកប្រែជាភាសាបារាំង ដែលបានស្រង់ដោយមេធាវីការពារក្តី។ ក្រៅអំពីដីកាដំណោះស្រាយ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលដីកាទាំងពីរនេះត្រូវបានបកប្រែទាំងស្រុងជាភាសាបារាំង អង្គបុរេជំនុំជម្រះពុំបានប្រទះឃើញឯកសារដែលមិនទាន់បានបកប្រែជាភាសាបារាំង ក្នុងដំណាក់កាលនៃនីតិវិធីនេះ ដែលជាការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ឡើយ[១៦]។ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់នៅត្រង់ចំណុចនេះថា សិទ្ធិទទួលបានការបកប្រែទៅជាភាសាបារាំងនូវសេចក្តីសន្និដ្ឋានរបស់ភាគី ដូចដែលបានបញ្ជាក់នៅក្នុងដីកាសម្រេចស្តីពីការបកប្រែឯកសារ និងសេចក្តីសម្រេចពាក់ព័ន្ធនឹងការបកប្រែឯក-សារ[១៧] ត្រូវបានកម្រិតត្រឹមតែសេចក្តីសន្និដ្ឋានដែលពាក់ព័ន្ធទៅនឹងបណ្តឹង និងបណ្តឹងឧទ្ធរណ៍នានា ដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយក្រុមមេធាវីការពារក្តី ដែលបានស្នើសុំឱ្យមានការទទួលឯកសារដែលបកប្រែជាភាសាបារាំងនោះ។ ម្យ៉ាងទៀត សិទ្ធិនេះមិនត្រូវបានលាតសន្ធឹងចំពោះរាល់ "ឯកសារទាំងអស់របស់ភាគីឡើយ"។ ដើម្បីអះអាងថា ខ្លួនជាជនរងគ្រោះនៃការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរ ខៀវ សំផន មិនអាចលើក

---

[១៥] សាលដីកាលើសំណើសុំឱ្យបកប្រែឯកសារទាំងឡាយដែលលើកមកសំអាងនៅក្នុងដីកាដំណោះស្រាយ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១០ ឯកសារលេខ ២ (អ.ប.ជ.១៦) កថាខណ្ឌ១០ និង ១១។

[១៦] ក្នុងចំណោមសេចក្តីសម្រេច និងដីកាសម្រេចទាំង ២៣២ ដែលចេញដោយចៅក្រម និងកំណត់ចំនួនដោយក្រុមមេធាវីការពារក្តី មានសេចក្តីសម្រេច និងដីកាសម្រេច ចំនួន ២១៣ មិនទាន់ត្រូវបានបកប្រែជាភាសាបារាំង គិតមកទល់បច្ចុប្បន្ន។ មួយភាគធំនៃឯកសារទាំងនោះជាសេចក្តីសម្រេចលើពាក្យបណ្តឹង និងបណ្តឹងឧទ្ធរណ៍ផ្សេងៗដែលត្រូវបានដាក់ដោយភាគី និងមិនមានការពាក់ព័ន្ធនឹងលោក ខៀវ សំផន ដីកាកំណត់កាលបរិច្ឆេទសវនាការ សាលដីកាជាលាយល័ក្ខអក្សរ ដែលត្រូវបានចេញជាផ្ទាល់មាត់នៅក្នុងពេលសវនាការ (និងដែលត្រូវបានបកប្រែផ្ទាល់មាត់ជាភាសាបារាំង) ដីកាបង្គាប់ឱ្យនាំជនត្រូវចោទ និងសេចក្តីសម្រេចទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

[១៧] ដីកាសម្រេចទាក់ទងនឹងការបកប្រែ កថាខណ្ឌ ៦២, សាលដីកាទាក់ទងនឹងការបកប្រែ កថាខណ្ឌ៣៧។

ឡើងអំពីអវត្តមាននៃការបកប្រែឯកសារចំនួន ៣៨៥០ របស់ភាគី ដែលក្នុងចំណោមនោះមានឯកសារចំនួន ៩៦ ជាសេចក្តីសន្និដ្ឋានរបស់ភាគីទាក់ទងនឹងរាល់រឿងរ៉ាវទាំងអស់នៅចំពោះមុខ អ.វ.ត.ក ដោយពុំបានធ្វើការបញ្ជាក់ថា តើឯកសារណាខ្លះដែលគាត់ពុំទទួលបានជាភាសាបារាំងនោះទេ។

១៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អវត្តមានជាបណ្តោះអាសន្ននៃការបកប្រែឯកសារអាចត្រូវបានដោះស្រាយ តាមរយៈធនធានភាសារបស់ក្រុមនីមួយៗ ដែលយ៉ាងហោចណាស់មានមេធាវីម្នាក់ ក្នុងចំណោមមេធាវីទាំងពីរអាចប្រើប្រាស់ភាសាខ្មែរដែលជាភាសាប្រើប្រាស់សម្រាប់ឯកសារមួយភាគធំនោះ។ ម្យ៉ាងទៀត ក្រុមមេធាវីការពារក្តី ខៀវ សំផន អាចប្រើប្រាស់សេវានៃអ្នកបកប្រែភាសា ដូចដែលបានកំណត់នៅក្នុងដីកាសម្រេចស្តីពីការបកប្រែឯកសារ។ ជាចុងក្រោយ ក្រុមមេធាវីការពារក្តីអាចស្នើសុំឲ្យមានការបកប្រែជាអទិភាពនូវរាល់ឯកសារទាំងឡាយ ដែលខ្លួនយល់ឃើញថា មានសារៈប្រយោជន៍ដល់ការការពារក្តីរបស់ខ្លួន ហើយដែលឯកសារទាំងនោះពុំទាន់ត្រូវបានបកប្រែនៅឡើយ។ នៅក្នុងលក្ខខណ្ឌទាំងនេះ ខៀវ សំផន ពុំបានបញ្ជាក់ថា តើអវត្តមានបណ្តោះអាសន្ននៃការបកប្រែឯកសារ បានបង្កើតឲ្យមានជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងជាក់ស្តែងទៅលើសិទ្ធិទាំងនេះ យ៉ាងដូចម្តេចនោះទេ។

១៤. យោងទៅលើអំណះអំណាងខាងលើនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា លើកលែងករណីដីកាដំណោះស្រាយ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលបច្ចុប្បន្ននេះត្រូវបានបកប្រែរួចជាស្ថាពរហើយនោះ អវត្តមានបណ្តោះអាសន្ននៃការបកប្រែឯកសារដែលបានស្រង់ដោយសហចៅក្រមស៊ើបអង្កេតសម្រាប់បកប្រែពុំបានបង្កើតឲ្យមានជាការរំលោភយ៉ាងធ្ងន់ធ្ងរ និងជាក់ស្តែងទៅលើ សិទ្ធិរបស់ ខៀវ សំផន ដែលជាមូលហេតុនាំឲ្យមានការព្យួរកិច្ចដំណើរការនីតិវិធីឡើយ។

១៥. ខៀវ សំផន បានលើកឡើងទៀតថា សិទ្ធិរបស់គាត់ក្នុងការទទួលបានការបកប្រែឯកសារ ជាសិទ្ធិដែល"គ្មានខ្លឹមសារ និងគ្រាន់តែជាការបំភ័ន្តភ្នែក" ដោយហេតុថា ការបកប្រែឯកសារពុំបានផ្តល់នូវព័ត៌មានមួយដែល "ពិតប្រាកដជាក់ស្តែង និងមិនក្លែងក្លាយ នៅក្នុងពេលវេលាមួយសមស្រប ដើម្បីអនុញ្ញាតឲ្យមេធាវីការពារជនជាប់ចោទអាចប្រើប្រាស់បានដោយមានប្រសិទ្ធភាព"។ គាត់បានបញ្ជាក់ថា ពុំមានប្រព័ន្ធ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ត្រួតពិនិត្យគុណភាព ហើយការបកប្រែឯកសារត្រូវបានធ្វើដោយមានកំហុសឆ្គង ដោយសារពុំមានសន្ទានុក្រមច្បាប់កម្ពុជា ពុំមានការសិក្សាទៅលើវាក្យសព្ទប្រើប្រាស់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយនៅប្រទេសកម្ពុជាពុំមានសាលាបណ្តុះបណ្តាលជំនាញឯកទេសខាងបកប្រែឯកសារ និងបកប្រែភាសាផ្ទាល់មាត់។ ជាចុងក្រោយ ខៀវ សំផន បានធ្វើការជំទាស់ទៅនឹងភាពអនាគតិនៃបុគ្គលទាំងឡាយដែលបានបកប្រែឯកសារមួយចំនួន ដោយហេតុថា បុគ្គលទាំងនោះបានបម្រើការងារចំណុះឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ឬមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)[១៨]។

១៦. អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ទឡ្ហីករណ៍របស់មេធាវីការពារក្តីមានលក្ខណៈទូទៅ ហើយពុំបានធ្វើការបញ្ជាក់អំពីកំហុសឆ្គងជាក់លាក់ណាមួយពាក់ព័ន្ធនឹងការបកប្រែឯកសារ ដែលកំហុសឆ្គងនោះបង្កើតឱ្យមានជាការរំលោភធ្ងន់ធ្ងរ ឬជាក់ស្តែងទៅលើសិទ្ធិរបស់ខ្លួននោះទេ។ ម្យ៉ាងទៀត អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងករណី ដែលបញ្ហាដែលកើតឡើងចំពោះការបកប្រែត្រូវបានរកឃើញបញ្ហាទាំងនោះអាចត្រូវបានលើកឡើងទៅតាមករណីនីមួយៗនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ។ ម្យ៉ាងទៀត មេធាវីការពារក្តីមានលទ្ធភាពក្នុងការស្នើសុំឱ្យមានការផ្ទៀងផ្ទាត់ការបកប្រែឯកសារទាំងឡាយណា ដែលខ្លួនយល់ឃើញថា មានកំហុសឆ្គងនោះ។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា កំហុសឆ្គងក្នុងការបកប្រែដែលអាចដោះស្រាយបាន ដោយគ្រាន់តែធ្វើសំណើសុំទៅកាន់ផ្នែកបកប្រែ ពុំមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ រហូតបណ្តាលឱ្យមានជាការរំលោភជាក់ស្តែង ទៅលើសិទ្ធិរបស់ ខៀវ សំផន ដែលជាមូលហេតុដើម្បីស្នើសុំឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីនោះឡើយ។

១៧. ខៀវ សំផន បានលើកឡើងបន្ថែមទៀតអំពី “ការរំលោភជាប្រព័ន្ធ និងទាំងស្រុង” ទៅលើសិទ្ធិរបស់មេធាវីការពារក្តី។ ដើម្បីធ្វើការចោទប្រកាន់ដូច្នេះ ខៀវ សំផន បានយោងទៅលើហេតុផលខាងសម្ភារៈ ដែលពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ទៅក្នុងសំណុំរឿង ដោយហេតុថា គាត់ត្រូវបានផ្តល់នូវថតដាក់ឯកសារតែចំនួន៤ថតប៉ុណ្ណោះ សម្រាប់ដាក់ឯកសារ ដែលចាំបាច់ដល់ការការពារក្តីរូបគាត់។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខៀវ សំផន ពុំបានធ្វើបណ្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេចស្តីពី

[១៨] សំណើសុំ កថាខណ្ឌ៣១ ដល់ ៤០។

ការចូលរួមរបស់ជនជាប់ឃុំឃាំងទៅក្នុងសំណុំរឿង[១៩] ហើយ ខៀវ សំផន ពុំបានប្រើប្រាស់ឱ្យអស់លទ្ធភាពក្នុងការធ្វើពាក្យបណ្តឹងដែលអនុញ្ញាតដល់រូបគាត់ទាក់ទងទៅនឹងបញ្ហានេះទេ។ ដូច្នេះ បន្ទាប់ពីរយៈពេលប្តឹងឧទ្ធរណ៍បានកន្លងផុតទៅ ខៀវ សំផន ពុំអាចលើកឡើងអំពីអវត្តមាននៃការចូលរួមទៅក្នុងសំណុំរឿងដូចដែលបានលើកឡើង ដើម្បីស្នើសុំឱ្យមានការបញ្ឈប់កិច្ចដំណើរការនៃនីតិវិធីឡើយ។ ម្យ៉ាងទៀត ខៀវ សំផន មិនអាចធ្វើការជំទាស់នៅពេលនេះបានទេ ដោយហេតុថា ខ្លួនអាចប្តឹងឧទ្ធរណ៍បាននោះ។

១៨. បន្ទាប់មកទៀត ខៀវ សំផន បានលើកឡើងអំពីគោលការណ៍នីត្យានុកូលភាព ដើម្បីសន្និដ្ឋានថា ការអនុវត្តនីតិអន្តរជាតិ ជាជាងនីតិជាតិ គឺជាការរំលោភទៅលើគោលការណ៍ "*គ្មានបទល្មើសណាមួយដែលពុំមានច្បាប់ចែងឡើយ* (*nullum crimen sine lege*)" ដែលនាំឱ្យខូចខាតប្រយោជន៍ដល់ភាពដែលអាចព្យាករទុកជាមុននូវការខូចខាតនានា និងទោសដែលត្រូវអនុវត្ត[២០]។ ជាមួយគ្នានេះ សិទ្ធិរបស់គាត់ត្រូវបានរំលោភបំពានដោយមូលហេតុនៃការអនុវត្តវិធានផ្ទៃក្នុង ជាជាងការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលជាហេតុធ្វើឱ្យគាត់បាត់បង់នូវសន្តិសុខគតិយុត្តិតាមរយៈការរំលោភលើគោលការណ៍ "*គ្មានរឿងក្តីណាមួយដែលច្បាប់ពុំបានចែងនោះឡើយ* (*nullum judicium sine lege*)" ដែលគោលការណ៍នេះត្រូវបានទទួលស្គាល់ដោយសាលដីការបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប[២១]។

១៩. ពាក់ព័ន្ធនឹងភាពដែលអាចព្យាករទុកបាននៃបណ្តឹង និងទោសដែលត្រូវផ្តន្ទា អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ខៀវ សំផន បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើគោលការណ៍ "*គ្មានបទល្មើសណាមួយ ដែលច្បាប់ពុំបានចែងនោះឡើយ*' ដោយមូលហេតុថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវច្បាប់អន្តរជាតិ ដោយពុំបានធ្វើការពន្យល់ថា តើច្បាប់នេះបានបង្កើតនូវអនុភាព ដែលជាការមិនគោរពដល់គោលការណ៍នីត្យានុកូលភាព ហើយដែលបង្កឱ្យមានជាការរំលោភលើនីតិវិធីយ៉ាងដូចម្តេចនោះ

---

[១៩] ដីកាសម្រេចស្តីពីការសុំមើលឯកសារសំណុំរឿងដោយជនជាប់ឃុំ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ ឯកសារ D127 កថាខណ្ឌ១៥ ដល់ ១៧។

[២០] សំណើសុំ កថាខណ្ឌ៥០ ដល់ ៥៣។

[២១] សំណើសុំ កថាខណ្ឌ៥៤ ដល់ ៥៨។

ទេ។ ដោយឡែក អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា អង្គបុរេជំនុំជម្រះបានទទួលពាក្យបណ្តឹងស្តីពីការរំលោភលើគោលការណ៍នីត្យានុកូលភាពនេះ នៅក្នុងក្របខណ្ឌនៃបណ្តឹងឧទ្ធរណ៍ ដែលប្រឆាំងទៅនឹងដីកាដំណោះស្រាយ ពីសំណាក់ជនជាប់ចោទចំនួនបីនាក់ផ្សេងទៀតក្នុងសំណុំរឿងតែមួយ[២២] ដែលពួកគេទាំងនោះ បានលើកឡើងនូវអំណះអំណាងលម្អិត ដើម្បីធ្វើជាមូលដ្ឋានចំពោះទឡ្ហីករណ៍ ដែលពួកគេបានលើកឡើងលើបញ្ហានេះ។ អង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចអំពីបញ្ហានេះ នៅក្នុងក្របខណ្ឌនៃសេចក្តីសម្រេច ដែលនឹងត្រូវចេញជាបន្តបន្ទាប់ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ទាំងនេះ ដោយយល់ឃើញថា រាល់សេចក្តីសម្រេចដែលពាក់ព័ន្ធនឹងបញ្ហានេះ នឹងអាចយកទៅអនុវត្តបានទៅលើករណី នៃជនជាប់ចោទទាំងអស់ដែលពាក់ព័ន្ធនឹងរឿងក្តីនេះ។

២០. ពាក់ព័ន្ធនឹងភាព ដែលអាចព្រៀងទុកបាននៃនីតិវិធីព្រហ្មទណ្ឌ អង្គបុរេជំនុំជម្រះបានផ្អែកទៅលើសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាបដិសេធបណ្តឹងសុំមោឃភាព ដែលនៅក្នុងសេចក្តីសម្រេចនោះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "វិធានផ្ទៃក្នុងបង្កើត [...] ឱ្យមានជាក្របខណ្ឌស្វយ័តមួយនៃវិធាននីតិវិធីពិសេស សម្រាប់ អ.វ.ត.ក."[២៣]។ ផ្ទុយទៅនឹងស្ថានភាព នៅក្នុងរឿងក្តី *Coëme និងអ្នកដទៃទៀត ប្រឆាំងនឹងប្រទេសបែលហ្សិក*[២៤] ដែលរឿងក្តីនេះត្រូវបានយោងដោយមេធាវីការពារក្តី វិធាននីតិវិធី ដែលអនុវត្តក្នុង អ.វ.ត.ក. មានបទបញ្ញត្តិរបស់ខ្លួនច្បាស់លាស់ ផ្ទុយអំពីករណីនៃរឿងក្តីនោះ។ ម្យ៉ាងទៀត វិធានផ្ទៃក្នុងត្រូវបានតាក់តែងឡើងមុនពេលចាប់ផ្តើមកិច្ចដំណើរការ

---

[២២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០។ ឯកសារលេខ D427/1/6 (អ.ប.ជ.៧៥)។ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១០ ឯកសារលេខ D427/2/1 (អ.ប.ជ.១៤៥) និងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១០ ឯកសារលេខ D427/3/1 (អ.ប.ជ.១៤៦)។

[២៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ១២ ដល់ ១៥។

[២៤] រឿងក្តី *Coëme និងអ្នកផ្សេងទៀត តទល់នឹងប្រទេសប៊ែលហ្ស៊ិក* សាលដីកាតុលាការសិទ្ធិមនុស្សអឺរ៉ុប (បណ្តឹងលេខ ៣២៤៩២/៩៦, ៣២៥៤៧/៩៦, ៣២៥៤៨/៩៦, ៣៣២០៩/៩៦ និង ៣៣២១០/៩៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ កថាខណ្ឌ៩៦ ដល់ ១០៣។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

នីតិវិធី ហើយមានលក្ខណៈដែលអាចជៀសវាងទុកបាន។ ក្នុងគ្រប់កាលៈទេសៈទាំងអស់ មេធាវីការពារក្តីពុំបានបង្ហាញឱ្យឃើញថា ការអនុវត្តវិធានផ្ទៃក្នុងបានបង្កជាព្យសនកម្មចំពោះខ្លួនយ៉ាងដូចម្តេចនោះទេ ហើយការអនុវត្តនេះបានដកហូតសិទ្ធិរបស់មេធាវីការពារក្តី ក្នុងការទទួលបានការជំនុំជម្រះសេចក្តីដោយយុត្តិធម៌ ឬបានបង្កើតឱ្យមានជាការរំលោភជាក់ស្តែងទៅលើសិទ្ធិរបស់គេនោះទេ។

២១. ក្នុងការស្នើសុំឱ្យមានការបញ្ឈប់កិច្ចដំណើរការនីតិវិធី ខៀវ សំផន បានផ្អែកផងដែរ ទៅលើកំហុសដែលទម្លាក់ទៅលើអង្គបុរេជំនុំជម្រះ ដែលពុំបានប្រើសិទ្ធិអំណាចរបស់ខ្លួនដើម្បីធ្វើការផ្តន្ទាទោសទៅលើអំពើរំលោភបំពាននីតិវិធី ដែលខ្លួនគាត់ជាជនរងគ្រោះនោះ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ខៀវ សំផន ពុំបានខ្នះខ្នែងក្នុងការបង្ហាញអំពីកំហុសដូចដែលគាត់បានចោទប្រកាន់នោះទេ។ ហេតុដូច្នេះ ទឡ្ហីករណ៍នេះដែលពុំមានមូលដ្ឋានរឹងមាំ ពុំអាចត្រូវបានធ្វើការពិនិត្យស៊ីជម្រៅឡើយ។

២២. មេធាវីការពារក្តីបានលើកសំអាងថា សិទ្ធិរបស់ ខៀវ សំផន ដែលត្រូវទទួលបានការកាត់សេចក្តីក្នុងរយៈពេលមួយសមស្របនោះ ត្រូវបានប្រើប្រាស់ជាអំណះអំណាងក្នុងការដកហូតសិទ្ធិទាំងឡាយរបស់គាត់ ហើយរយៈពេលសម្រាប់ចេញសេចក្តីសម្រេចមួយចំនួនបានបង្កើតឱ្យមានជាការរំលោភទៅលើសិទ្ធិមួយនេះ។ ប្រសិនណាជាសិទ្ធិដែលត្រូវទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប គឺជាសិទ្ធិដែលជនជាប់ចោទត្រូវទទួលបាន ចៅក្រមមានកាតព្វកិច្ចនៅដំណាក់កាលនីមួយៗនៃនីតិវិធីក្នុងការធានាថាពុំមានរយៈពេលដែលមិនសមស្របទៅនឹងតម្រូវការនៃនីតិវិធី ឬការអនុវត្តសិទ្ធិទាំងឡាយរបស់ភាគីពុំបានធ្វើឱ្យយឺតយ៉ាវដល់ដំណើរការរបស់អង្គជំនុំជម្រះឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ពុំមានការបង្ហាញថា រយៈពេលដែលបានលើកឡើងនោះមានលក្ខណៈពុំសមហេតុសមផលយ៉ាងដូចម្តេចនោះទេ ហើយនៅគ្រប់ករណីទាំងអស់ រយៈពេលសរុបពាក់កណ្តាលឆ្នាំដើម្បីបញ្ចប់កិច្ចស៊ើបសួរលើរឿងក្តី ដែលមានទំហំធំធេងយ៉ាងដូច្នេះ មិនមែនហួសហេតុនោះឡើយ។ ដូចនេះ ការរំលោភដូចដែលបានលើកឡើង ពុំបានបង្ហាញនូវចរិតលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ឬជាក់ស្តែង ដើម្បីធ្វើជាមូលហេតុ ក្នុងការបញ្ឈប់នីតិវិធីឡើយ។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C.

00634795



២៣. ខៀវ សំផន បានស្នើសុំឱ្យមានការបញ្ឈប់នូវនីតិវិធី ដោយផ្អែកលើមូលដ្ឋាននៃការលើកឡើងអំពីសច្ចាធារណ៍ជាសាធារណៈចំពោះពិរុទ្ធភាពរបស់គាត់ ដោយផ្សាយចេញពីការិយាល័យរដ្ឋបាល ដោយហេតុថា ការចុះផ្សាយលើគេហទំព័ររបស់ អ.វ.ត.ក. នូវ"អត្ថបទព័ត៌មានដែលពាក់ព័ន្ធនឹងសំណុំរឿងតុលាការ"បញ្ជាក់ថា រូបគាត់ធ្លាប់មានតួនាទីជាប្រធានមន្ទីរ៨៧០ ហើយម្យ៉ាងទៀត "អំពីការឃោសនាដែលផ្តល់ប្រយោជន៍ដល់ អ.វ.ត.ក. ប្រឆាំងទៅនឹងជនត្រូវចោទ"។ បើទោះបីជាការលើកឡើងរបស់ ខៀវ សំផន មានមូលដ្ឋានសមស្របក៏ដោយ ក៏ការលើកឡើងនេះពុំបានជះឥទ្ធិពល ទៅលើកិច្ចដំណើរការនីតិវិធីរបស់តុលាការដែរ ហើយក៏ពុំបានបង្កឱ្យមានជាការរំលោភជាក់ស្តែង និងធ្ងន់ធ្ងរ ទៅលើសិទ្ធិរបស់មេធាវីការពារក្តី ដែលជាមូលហេតុដើម្បីឱ្យមានការព្យួរកិច្ចដំណើរការនីតិវិធីដែរ។

២៤. អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ពុំមានការលើកឡើងណាមួយស្តីអំពីការរំលោភលើសិទ្ធិរបស់ ខៀវ សំផន បានបង្ហាញអំពីបញ្ហាធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងយុត្តិធម៌ ឬបានបង្ហាញអំពីចរិតជាក់ស្តែង ឬធ្ងន់ធ្ងរ ដើម្បីជាមូលហេតុនាំឱ្យមានការបញ្ឈប់នូវកិច្ចដំណើរការនៃនីតិវិធី ដោយហេតុមានការរំលោភលើនីតិវិធីនោះទេ ក្នុងករណីដែលការលើកឡើងទាំងនោះមានមូលដ្ឋានសមស្របក៏ដោយ។ ដូច្នេះ ពុំមានករណីចាំបាច់ដែលតម្រូវឱ្យធ្វើការពិនិត្យលើខ្លឹមសារអង្គច្បាប់នៃការលើកឡើងទាំងនោះទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច÷**

**ប្រកាសថា** សំណើសុំ មិនអាចទទួលយកបាន។

ភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១១

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**ប្រាក់ គឹមសាន**

**Rowan DOWNING** **នីយ ធុល** **Catherine MARCHI-UHEL** **ហួត វុធី**